ACCESS 2
Sustainable quality services for all

Australian Aid

ព្រឹត្តិបត្តិព័ត៌មានខេត្ត

ACCESS 2 ក្នុងខេត្តរតនគីរី

កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២

ព័ត៌មានសង្ខេបអំពីខេត្តរតនគីរី

២៦%
នៃស្ត្រីធ្លាប់ទទួលរងអំពើហិង្សាពីដៃគូស្និទ្ធស្នាល [1]

២១,៦%
នៃចំនួនប្រជាជនមានពិការភាពក្នុងទម្រង់ណាមួយ[2]

៥
ដៃគូ ACCESS 2 កំពុងធ្វើការនៅក្នុងខេត្តនេះ

[1] ស្ត្រីដែលធ្លាប់មានដៃគូ អាយុពី១៥ ដល់៤៩ឆ្នាំ ធ្លាប់បានទទួលរងអំពើហិង្សាផ្លូវកាយ ផ្លូវភេទ ឬផ្លូវអារម្មនៅដំណាក់កាលណាមួយក្នុងជីវិតរបស់ពួកគេ។ យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២០២២។

[2] តាមរបាយការណ៍បានឱ្យដឹងថា ក្រុមប្រជាជនដែលមានអាយុចាប់ពី៥ឆ្នាំឡើងទៅ មានការលំបាកក្នុងកម្រិតណាមួយ (មានការលំបាកខ្លះ មានការលំបាកខ្លាំង ឬមិនអាចធ្វើអ្វីបានសោះ)។ យោងតាមការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១៤ និងឆ្នាំ២០២១-២០២២។

តើកម្មវិធី ACCESS 2 ធ្វើអ្វីខ្លះក្នុងខេត្តរតនគីរី



កម្មវិធី ACCESS 2 កំពុងអនុវត្តការងារនៅខេត្តរតនគិរី ដើម្បីនាំយកសេវាដែលមានបរិយាបន្នកាន់តែខិតជិតសហគមន៍ជនជាតិដើមភាគតិចក្នុងខេត្ត ដែលចំងាយផ្លូវ ភាសា និងបទដ្ឋានសង្គមអាចក្លាយជាឧបសគ្គក្នុងការទទួលបានសេវាគាំទ្រ។ កម្មវិធី ACCESS 2 ផ្តល់ការគាំទ្រដល់ការឆ្លើយតបអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) និងបរិយាបន្នពិការភាព ដោយផ្តោតការយកចិត្តទុកដាក់លើការអភិវឌ្ឍជនជាតិដើមភាគតិច ដោយធ្វើការតាមរយៈអង្គការជនជាតិដើមភាគតិច និងអ្នកស្ម័គ្រចិត្តសហគមន៍ដែលអាចប្រើប្រាស់បានបីភាសា។



គណៈកម្មាធិការសម្របសម្រួលថ្នាក់ខេត្ត លើកទឹកចិត្តដល់អាជ្ញាធរថ្នាក់ក្រោមជាតិ និងដៃគូ អនុវត្តឱ្យធ្វើការរួមគ្នា ដើម្បីធានាការបញ្ជូនករណី និងការភ្ជាប់សេវារវាងភាគីពាក់ព័ន្ធ កាន់តែមានភាពប្រសើរឡើង។ រីឯដៃគូនៅសហគមន៍បានភ្ជាប់អ្នកនៅរស់រានមានជីវិតទៅនឹងអាជ្ញាធរ មូលដ្ឋាន សេវាសុខាភិបាល និងអ្នកផ្តល់សេវាផ្សេងៗ ដើម្បីធានាថាគ្មានអ្នកណាម្នាក់ត្រូវប្រឈមនឹងប្រព័ន្ធសេវាតែឯងនោះទេ។ ក្រុមប្រឹក្សាសកម្មភាពពិការខេត្ត និងក្រុមការងារឆ្លើយតប GBV ក៏ផ្តល់ការគាំទ្រដល់ការសម្របសម្រួលនេះដែរ។

ការគាំទ្រនេះបាននាំមកនូវសមិទ្ធផលជាច្រើនជាលើកដំបូងមកកាន់ខេត្តនេះ រួមទាំងកន្លែងផ្តល់សេវាចម្រុះ (OSSU) ជាលើកដំបូង បន្ទប់ប្រឹក្សាយោបល់សម្រាប់អ្នកនៅរស់រានពី GBV ដែលរក្សាការសម្ងាត់បានចំនួន៣៦ នៅថ្នាក់ឃុំ និងស្រុក ការសម្របសម្រួលឱ្យអង្គការតំណាងជនមានពិការភាព (OPDs) បានដំណើរការឡើងវិញ និងកិច្ចសន្ទនានៅតាមសហគមន៍ ដែលកំពុងរួមចំណែកផ្លាស់ប្តូរឥរិយាបថអំពីអំពើហិង្សា និងពិការភាព នៅក្នុងភូមិជនជាតិដើមភាគតិច។

ការងារអាទិភាពដែលកំពុងអនុវត្តក្នុងខេត្តរតនគីរី

- អំពើហិង្សាទាក់ទងនឹងយេនឌ័រ
- បរិយាបន្នពិការភាព
- ការអភិវឌ្ឍជនជាតិដើមភាគតិច

លទ្ធផលសម្រេចបាននៅខេត្តរតនគីរី គិតត្រឹមខែមិថុនា ឆ្នាំ២០២៦

៤.៩២៤ នាក់
បានចូលរួមក្នុងកិច្ចសន្ទនាសហគមន៍ចំនួន១៥២លើក នៅតាមភូមិជនជាតិដើមភាគតិច

៦.៩៣៣ នាក់
ជាជនមានពិការភាពត្រូវបានកំណត់អត្តសញ្ញាណ ក្នុងនោះ១.១០៦នាក់ទទួលបានអត្ថប្រយោជន៍ពីកញ្ចប់គ្រួសារ

៧១៩ នាក់
ជាអ្នកនៅរស់រានពី GBV ទទួលបានការគាំទ្រ រួមទាំងការប្រឹក្សាយោបល់ និងតំណាងផ្នែកច្បាប់ដោយឥតគិតកម្រៃ

តើយើងធ្វើការជាមួយអ្នកណាខ្លះក្នុងខេត្តរតនគិរី

ដៃគូជារដ្ឋបាលខេត្ត

- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត
- មន្ទីរកិច្ចការនារីខេត្ត
- មន្ទីរសុខាភិបាលខេត្ត
- ក្រុមប្រឹក្សាសកម្មភាពជនពិការខេត្ត
- ក្រុមការងារឆ្លើយតបនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រ
- មូលនិធិជនពិការ
- គណៈកម្មាធិការឃុំ សង្កាត់ ទទួលបន្ទុកការងារស្ត្រី និងកុមារ (គ.ក.ន.ក)

ដៃគូអនុវត្ត និងសង្គមស៊ីវិល

- អង្គការ CARE Cambodia
- អង្គការ PAfID
- អង្គការចិត្តសង្គម អន្តរវប្បធម៌កម្ពុជា (TPO)
- អង្គការ UNICEF
- អង្គការតំណាងជនមានពិការភាព (OPDs)
- សមាគមខ្មែរលើ
- អង្គការអភិរក្សភាសាជនជាតិដើមភាគតិច

សកម្មភាពចម្បងៗក្នុងខេត្តរតនគិរី

ផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ

- ដាក់ឱ្យដំណើរការ OSSU សម្រាប់អ្នកនៅរស់រានពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅមន្ទីរពេទ្យបង្អែកខេត្ត
- ចុះផ្សព្វផ្សាយក្នុងសហគមន៍អំពីអំពើហិង្សា និងសុខភាពផ្លូវចិត្ត ដោយប្រើភាសារបស់ជនជាតិដើមភាគតិច
- បង្កើតឱ្យមានបន្ទប់ប្រឹក្សាយោបល់អំពើGBV ដែលរក្សាការសម្ងាត់ បានចំនួន៣៦ នៅថ្នាក់ឃុំ និងស្រុក
- គាំទ្រក្រុមការងារឆ្លើយតបGBV បានចំនួន១០ក្រុម (ថ្នាក់ខេត្ត១ និងថ្នាក់ស្រុក៩) និងបណ្តុះបណ្តាលសមាជិកចំនួន៥៥០នាក់ អំពីការផ្តល់ប្រឹក្សា ការបញ្ជូនករណី និងការគាំទ្រផ្នែកច្បាប់

ផ្នែកបរិយាបន្នពិការភាព

- គាំទ្រការកំណត់អត្តសញ្ញាណជនមានពិការភាពទូទាំងខេត្ត ដែលបានវាយតម្លៃមនុស្សចំនួន៦.៩៣៣នាក់ ក្នុងនោះ ជនមានពិការភាពចំនួន ៤.៨៣៥នាក់ បានទទួលបណ្ណសម្គាល់ជនមានពិការភាព
- បង្កើត និងពង្រឹងក្រុមប្រឹក្សាសកម្មភាពជនពិការខេត្តដែលមានសមាជិកចំនួន៥៤នាក់
- បណ្តុះបណ្តាលបុគ្គលិកសង្គមកិច្ចខេត្ត និងស្រុកបានចំនួន៤៥នាក់ អំពីនីតិវិធីកិច្ចការពារកុមារ

ផ្នែកការអភិវឌ្ឍជនជាតិដើមភាគតិច

- សម្របសម្រួលកិច្ចសន្ទនាសហគមន៍នៅតាមភូមិជនជាតិដើមភាគតិច (ដោយប្រើវិធីសាស្ត្រវិភាគសង្គម និងអនុវត្តជាក់ស្តែង)
- គាំទ្រអ្នកស្ម័គ្រចិត្តដែលអាចប្រើប្រាស់បានបីភាសា ដើម្បីបកប្រែឯកសារ និងដឹកនាំកិច្ចសន្ទនានៅក្នុងភូមិជនជាតិដើមភាគតិចនៅតំបន់ដាច់ស្រយាល
- ជួយឃុំ ដាក់បញ្ចូលសកម្មភាពអាទិភាពពាក់ព័ន្ធនឹងយេនឌ័រ និងពិការភាព ទៅក្នុងផែនការវិនិយោគមូលដ្ឋាន ដោយមានការបែងចែកថវិកាសម្រាប់សកម្មភាពចំនួន១៦៤
- ធ្វើការស្រាវជ្រាវបទដ្ឋានសង្គម និងបញ្ហាពិការភាពនៅក្នុងសហគមន៍ជនជាតិដើមភាគតិច ដោយបានធ្វើការអង្កេតលើមនុស្សប្រមាណជាង ៣០០នាក់ ដើម្បីកំណត់ពីតម្រូវការសេវាចាំបាច់



"កម្មវិធី ACCESS 2 បានផ្លាស់ប្តូរលទ្ធភាពទទួលបានសេវាសម្រាប់សហគមន៍ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះ ដោយបង្កើតសេវាចាំបាច់ផ្នែកសុខាភិបាល ច្បាប់ កិច្ចគាំពារសង្គម និង សេវាគាំទ្រនានាឱ្យកាន់តែជិតទៅដល់តំបន់ដាច់ស្រយាល។ តាមរយៈវិធីសាស្ត្រដែលសមស្របតាមវប្បធម៌ ការចុះផ្សព្វផ្សាយលើកកម្ពស់បរិយាបន្នពិការភាព និងការពង្រឹងការយល់ដឹងរបស់សហគមន៍ កម្មវិធីនេះបានរួមចំណែកកាត់បន្ថយឧបសគ្គ លើកកម្ពស់សិទ្ធិ និងបង្កើនលទ្ធភាពទទួលបាសេវា និងលើកកម្ពស់សហគមន៍ឱ្យកាន់តែមានបរិយាបន្ន និងមានភាពធន់ ។"

លោកជំទាវ ញាន ទិត្យចិន្តា អភិបាលរងនៃគណៈអភិបាលខេត្តរតនគិរី

អគារ ANINA ជាន់ទី៣ ផ្លូវ២៧១ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

info@access2cambodia.org www.access2cambodia.org

ACCESS 2 ត្រូវបានគាំទ្រដោយរដ្ឋាភិបាលអូស្ត្រាលី និងគ្រប់គ្រងដោយ Abt Global